ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី

ក្រសួងបរិស្ថាន

លេខៈ...១៦១/ប្រ.ក...ប.ស្ថ

រាជធានីភ្នំពេញ ថ្ងៃទី...២០... ខែ...មិថុនា......ឆ្នាំ២០០៦

# ប្រកាស

## ស្តីពីការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ "មណ្ឌលយ៉ែន" ឃុំតាវែងលើ ស្រុកតាវែង ស្ថិតក្នុងតំបន់ឧទ្យានជាតិវីរៈជ័យ ខេត្តរតនៈគិរី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦-៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញសេចក្តីជូនដំណឹងលេខ ២៩៥ សជណ.កស ចុះថ្ងៃទី ១៦ ខែ មិនា ឆ្នាំ២០០១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- ផ្អែកតាមតម្រូវការចាំបាច់របស់សហគមន៍មូលដ្ឋានដែលស្ថិតនៅក្នុងតំបន់ឧទ្យានជាតិវីរៈជ័យ ខេត្តរតនៈគិរី។

## សំរេច

ប្រការ១:- រៀបចំសហគមន៍តំបន់ការពារធម្មជាតិដែលស្ថិតនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព នៃឧទ្យានជាតិវីរៈជ័យ ស្ថិតនៅក្នុងឃុំតាវែងលើ ស្រុកតាវែង ខេត្តរតនៈគិរី មានឈ្មោះថា "**សហគមន៍តំបន់ការពារធម្មជាតិមណ្ឌលយ៉ែន** "។

ប្រការ២:- សហគមន៍តំបន់ការពារធម្មជាតិ**មណ្ឌលយ៉ែន** នៃឧទ្យានជាតិវីរៈជ័យ ក្នុងភូមិសាស្ត្រឃុំតាវែងលើ ស្រុកតាវែង ខេត្តរតនៈគិរី មានផ្ទៃដីប្រាំរយហាសិប (**៥៥០**) **ហិកតា** ដូចបានកំណត់ក្នុងផែនទី ដែលមានអាប់ស៊ីស និងកូអ័រដោនេព្រំប្រទល់ ខាងក្រោម:

| ចំណុច | ឈ្មោះទីតាំង | អាប់ស៊ីស X | អរដោនេ Y | ចំណុច | ឈ្មោះទីតាំង | អាប់ស៊ីស X | អរដោនេ Y |
|---|---|---|---|---|---|---|---|
| A | មណ្ឌលយ៉េនទីតាំង ប្រជាជនរស់នៅ | 0740 692 | 1564 499 | J | ត្រពាំងភោគឃៀប | 0742 557 | 1567 379 |
| B | ចំនុចប្រសព្វរវាងអូរតាម៉ល់ និងអូរតាម៉ល់ម៉ែក | 0740 884 | 1566 336 | K | ផ្លូវពីត្រពាំងភោគឃៀប ទៅអូរតាយ៉ាក | 0742 540 | 1567 478 |
| C | អូរតាម៉ល | 0740 612 | 1566 244 | L | អូរតាបូក | 0742 560 | 1567 699 |
| D | អូរតាម៉ល់ម៉ែក | 0740 832 | 1566 422 | M | ចំណុចប្រសព្វអូរតាយ៉ាក និងអូរតាបូក | 0742 577 | 1565 364 |
| E | អូរចាអ៊ិន | 0741 375 | 1566751 | N | ចំការពនេចររបស់អ្នកភូមិយ៉េន | 0742 585 | 1565 284 |
| F | អូរចាអ៊ិនត្រង់ចំនុចត្រឡប់ទៅកាន់ផ្លូវឡានវៀតណាម | 0741 396 | 1567 086 | O | វាលទំនាបសប៉ រ | 0742 574 | 1565 131 |
| G | ផ្លូវឡានវៀតណាម | 0742 409 | 1567 079 | P | អូររុមភិន | 0742 397 | 1564 363 |
| H | ផ្លូវឡានវៀតណាមបំបែកទៅតពាំងភោគឃៀប | 0742 511 | 1567 122 | Q | អូររុមភិនជួបជាមួយ ផ្លូវឡានវៀតណាម | 0742 230 | 1564 335 |
| I | ត្រពាំងភោគឃៀប | 0742 540 | 1567 196 | R | អូររុមភិនជួបជាមួយ អូរតាបូក | 0741 402 | 1564120 |

<u>ប្រការ៣:</u>– ការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ**មណ្ឌលយ៉េន** នៃឧទ្យានជាតិវីរៈជ័យ និងការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់នេះ ត្រូវចុះកិច្ចព្រមព្រៀងជាមួយក្រសួងបរិស្ថាន ហើយសហគមន៍នេះត្រូវមានលក្ខន្តិកៈដោយឡែក ។

<u>ប្រការ៤:</u>– អគ្គនាយកបច្ចេកទេស អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានការពារនិងអភិរក្សធម្មជាតិ ប្រធានមន្ទីរបរិស្ថានខេត្ត នាយកឧទ្យានជាតិវីរៈជ័យ អង្គភាពពាក់ព័ន្ធ និងសហគមន៍តំបន់ការពារធម្មជាតិ**មណ្ឌលយ៉េន** នៃឃុំតាវែងលើ ស្រុកតាវែង ខេត្តរតនៈគិរី ត្រូវសហការអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*<u>ចំលងជូន:</u>*

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- សាលាខេត្តរតនៈគិរី
- គំរោងគ្រប់គ្រងជីវៈចម្រុះ និងឧទ្យានជាតិវីរៈជ័យ
- ដូចប្រការ ៤" ដើម្បីអនុវត្ត"
- ឯកសារ, កាលប្បវត្តិ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ម៉ុក_ម៉ារ៉េត

បណ្ឌិត.ជីវវិទ្យា